ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ២២

ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៥

សាលដីកា

លេខ: ៦០

ចុះថ្ងៃទី០៣ខែសីហាឆ្នាំ២០០៥

# នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ:

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក រៀល មួន ចៅក្រម

៣- លោក ស៊ិន ឌឹម ចៅក្រម

៤- លោក ប៉ែន សាវឿន ចៅក្រម-របាយការណ៍

៥- លោក យស់ សូខឿន ចៅក្រម

**ក្រឡាបញ្ជី**

អ្នកស្រី សុជុំន សុមានីកា

**តំណាងមហាអយ្យការ**

លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ០៥ "ខ" ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ២២ ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

**<u>ចំពោះ:</u>** បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៨ តាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះ ភុំ កែវ ( ម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៦៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាំងស្រឡៅ ឃុំ-ស្រុក-ខេត្ត កំពង់ស្ពឺ មុខរបរ ផលិតទោងយោង មានទីលំនៅផ្ទះលេខ២៨៤E₀ ផ្លូវមុន្នីវង្ស ក្រុមទី២៤ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ ឪពុកឈ្មោះ ភុំ(ស) ម្តាយឈ្មោះ ស៊ុន (ស) ប្តីឈ្មោះឈើ លៀម មានកូន០៨នាក់ ។

-មេធាវី : លោកស្រី ខូច សុទ្ធារី

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ លីម ហួង ( ចុងបណ្តឹងសាទុក្ខ ) ភេទស្រី អាយុ៥៨ឆ្នាំ ជាតិខ្មែរ

ទីលំនៅសព្វថ្ងៃផ្ទះលេខ២៨៤ E₁z ផ្លូវមុន្នីវង្ស ក្រុមទី២៤ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ ។ ប្ដីឈ្មោះ ពេជ្រ ឡុង ហៅ ប៉ា ឡុង ។

-មេធាវីៈ គ្មាន

តាមពាក្យបណ្ដឹងចុះថ្ងៃទី១១-៥-១៩៩៨ របស់ឈ្មោះ លឹម ហួង ថាៈ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៨ នៅវេលាម៉ោង៥ᵐ ០០' ឈ្មោះភុំ កែវ បានឱ្យកូនធ្វើផ្ទះចូលទ្វារ បង្ហួចរបស់ខ្លួន ប្រហែលមួយម៉ែត្រខ្លួនបានតវ៉ា.ឈ្មោះ ភុំ កែវ បានយកភ្លើងដុតជើងជណ្ដើរ ខ្លួនបានយកទឹកមកចាក់ពន្លត់ ស្រាប់តែឈ្មោះ ភុំ កែវ បានប្រានខ្លួនឱ្យដួលបណ្ដាលឱ្យបាក់ដៃឆ្វេង ។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់អយ្យការ អមតុលាការក្រុងភ្នំពេញសំរេចៈ ចោទប្រកាន់លើឈ្មោះ ភុំ កែវ ភេទស្រី អាយុ៦២ឆ្នាំ ពីបទ បង្ករបួសស្នាមដោយចេតនា កាលពីថ្ងៃទី១០-៥-១៩៩៨ ទុកជាបានការពេញទាំងមូល និង សុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ០៩"ដ" ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១-ផ្ដន្ទាទោសឈ្មោះ ភុំ កែវ ភេទស្រី អាយុ៦៤ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារចំនួន០៦ខែ "ប្រាំមួយខែ" តែទោសនេះត្រូវព្យួរទាំងអស់ក្នុងរយៈពេលសាកល្បង៥ឆ្នាំ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ពីបទ បង្ករបួសស្នាមដោយចេតនា បទល្មើសប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១០-៥-១៩៩៨ តាមបញ្ញត្តិមាត្រា៤១ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-បង្គាប់អោយឈ្មោះ ភុំ កែវ ភេទស្រី អាយុ ៦៤ឆ្នាំ ជាតិខ្មែរ សងប្រាក់ថ្លៃថ្នាំព្យាបាល និង ជំងឺចិត្តចំនួន១.៥០០.០០០រៀល "មួយលានប្រាំសែនរៀល" អោយទៅឈ្មោះ លឹម ហួង ភេទស្រី អាយុ៥៨ឆ្នាំ ជាតិខ្មែរ ។ សំណូមពរលើសពីនេះត្រូវបដិសេធចោល ។

ករណីឈ្មោះ ភុំ កែវ រឹងទទឹងពុំព្រមសងប្រាក់ត្រូវដាក់គុកបង្ខំលើរូបកាយតាមច្បាប់ ស្ដីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និង ចំពោះមុខជនរងគ្រោះជាដើមបណ្ដឹងរដ្ឋប្បវេណីសំរេចបើកផ្លូវប្ដឹងឧទ្ធរណ៍នៅក្នុងកំណត់ច្បាប់ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ០៩"ដ" ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៩៩ របស់ឈ្មោះ ភុំ កែវ និង បណ្ដឹងឧទ្ធរណ៍លេខ១០"ដ" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៩ របស់ឈ្មោះ លឹម ហួង ប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ០៩"ដ" ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើសេចក្ដីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា:

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ភុំ កែវ ចុះថ្ងៃទី២០-៤-១៩៩៩ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ០៩"ដ" ចុះថ្ងៃទី២៥-៣-១៩៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២៣"ខ" ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ:

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ១០"ដ" ចុះថ្ងៃទី២២-៤-១៩៩៩ របស់ឈ្មោះ លឹម ហួង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ០៩ "ដ" ចុះថ្ងៃទី២៥-៣-១៩៩៩ របស់តុលាការក្រុងភ្នំពេញទុកជាបានការ ។

សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ។ បើកផ្លូវប្តឹងទាស់ និង ប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងទាស់លេខ១០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៣ របស់ឈ្មោះ ភុំ កែវ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ២៣"ខ" ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០៥ "ខ" ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ:

១-ទទួលបណ្តឹងទាស់លេខ១០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៣ របស់ជនជាប់ចោទឈ្មោះ ភុំ កែវ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយ និង គតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ២៣"ខ" ចុះថ្ងៃទី២៥-៤-២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី ជនជាប់ចោទ និង ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ ២៤ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះ ភុំ កែវ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ០៥"ខ"ចុះថ្ងៃទី១០ ខែកុម្ភៈឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណាការពារ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៥ របស់ឈ្មោះ ភុំ កែវ

-បានឃើញសារណាតប ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៥ របស់ឈ្មោះ លឹម ហួង

-បានស្តាប់របាយការណ៍របស់ចៅក្រុមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : ពិតជាមានធាតុផ្សំ និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ភុំ កែវ ពីបទ បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៨ តាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-សូមតម្កល់សាលដីកាព្រហ្មទណ្ឌលេខ០៥"ខ" ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ភុំ កែវ នាពេលសវនាការថា:ដោយពុំមានស្មារតីល្អក្នុងការឆ្លើយនូវសំណួររបស់ប្រធានក្រុមប្រឹក្សាជំនុំជំរះបាន ដូច្នេះប្រធានបញ្ឈប់ការសួរ រួចឱ្យថយទៅកាន់កន្លែង។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ លឹម ហួង នាពេលសវនាការថា: កូនប្រុសរបស់ ភុំ កែវ បានឡើងធ្វើដំបូងដែក ប្រក់ស័ង្កសីបិទបង្អួចផ្ទះនាងខ្ញុំ ខ្ញុំខ្លាចទឹកហូរចូលផ្ទះ បានហាមឃាត់កូនមិនឱ្យធ្វើ ស្រាប់តែនាង ភុំ កែវ ជេរបញ្ជោរ ហើយយកភ្លើង និង ក្រដាស មួយដៃធំមកចាក់សាំងដុតនៅជើងជណ្តើរផ្ទះខ្ញុំ ខ្ញុំខ្លាចឆេះផ្ទះក៏យកទឹកមួយកូនធុងតូចចុះទៅចាក់ពន្លត់ភ្លើង ពេលជះទឹកទៅស្រាប់តែ ភុំ កែវ ស្ទុះមកច្រាននាងខ្ញុំឱ្យដួលផ្ទប់នឹងបង្កាន់ដៃជណ្តើរ ហើយវាយខ្ញុំបន្ថែមពីលើ ជាច្រើនដៃ ធ្វើឱ្យបាក់កដៃខ្ញុំ ។ សូមតុលាការដាក់គុកជនល្មើសទៅតាមច្បាប់ នាងខ្ញុំមិនចង់បានសំណងអ្វីទេ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកស្រី ទូច សុទ្ធារី មេធាវីការពារឱ្យជនជាប់ចោទឈ្មោះភុំ កែវ នាពេលសវនាការថា: នៅថ្ងៃទី១០-៥-១៩៩៨ យាយ ភុំ កែវ ឱ្យកូនប្រុសគាត់ប្រក់ដំបូងផ្ទះដែលលិចទឹក តែប្តី លឹម ហួង ស្រែកជេរមិនឱ្យប្រក់ ហើយយកដំបងរកវាយជាង ប៉ុន្តែមិនបានវាយតប់គ្នាទេ គ្រាន់តែជេរគ្នាបន្តិចបន្តួច ។ យាយ ភុំ កែវ យកក្រដាសសែនតូចៗ ១២សន្លឹកមកដុតក្បែរជណ្តើរដែក កាំជណ្តើរក៏ដែក ( មិនមែនជាជណ្តើររបស់យាយ លឹម ហួង ទេ) ដូច្នេះ ភ្លើងដុតក្រដាសសែនតូចៗ មិនអាចធ្វើឱ្យឆេះជណ្តើរ ឆេះផ្ទះ របស់យាយលឹម ហួង បានទេ ។ មានសាក្សីឈ្មោះ ប្រាក់ សារ៉ុធ ឃើញវាយតប់គ្នាឃើញ ភុំ កែវ ទាញ លឹម ហួង ធ្លាក់ពីលើជណ្តើរ គឺមិនពិតទេ ព្រោះសាក្សីរូបនេះជាមនុស្សពនេចរ មិនមែនជាអ្នកស្រុកនៅក្នុងតំបន់នេះទេ។នាងខ្ញុំសុំបដិសេធចម្លើយសាក្សីឈ្មោះប្រាក់ សារ៉ុធ សូមតុលាការមេត្តាពិនិត្យសារឡើងវិញ ព្រោះនៅពេលកើតហេតុ ពុំមានការវាយតប់គ្នាទេ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម របស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: ពុំមានយោបល់អ្វីបន្ថែមទៀតទេ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រុមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៤ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះភុំ កែវ ធ្វើឡើងក្នុងកំនត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា តាមការលើកឡើងក្នុងសារណា ចុះថ្ងៃទី២២-៣-២០០៥ ក៏ដូចជាក្នុងសវនាការនេះដែរ ជនជាប់ចោទឈ្មោះ ភុំ កែវ អះអាងថា ខ្លួនមិនបានប្រព្រឹត្ត អំពើបង្ករបួសស្នាមទៅលើឈ្មោះ លឹម ហួង ទេ ការចោទប្រកាន់នេះពិតជាមិនត្រឹមត្រូវ ព្រោះពុំមានភស្តុតាង ពុំមានសាក្សីច្បាស់លាស់ឡើយ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថាតាមចម្លើយជនរងគ្រោះក៏ដូចជាសាក្សីជនរងគ្រោះឈ្មោះប្រាក់ សារុធ បញ្ជាក់ថា ឈ្មោះ ភុំ កែវ ពិតជាបានចាប់បោកឈ្មោះ លឹម ហួង ទៅនឹងជណ្តើរជាច្រើនដងប្រាកដមែន ។

-យល់ឃើញថា ការដែលមេធាវីការពារជនជាប់ចោទលើកឡើងថា កូនក្តីរបស់លោកស្រី ពុំបានវាយតប់ជនរងគ្រោះ ហើយថាមានភាពមិនប្រក្រតីចំពោះវិញ្ញាបនប័ត្រពេទ្យ និងសាក្សីជនរងគ្រោះនោះ តុលាការថ្នាក់ក្រោមបានពិចារណារួចហើយ ហើយវិញ្ញាបនប័ត្រនេះធ្វើឡើងតាមការស្នើសុំរបស់ការិយាល័យព្រហ្មទណ្ឌកិរិតស្រាល ពុំមែនតាមការស្នើសុំរបស់ជនរងគ្រោះទេ ។

-យល់ឃើញថា តាមលិខិតកោសល្យវិច័យរបស់មន្ទីរសុខាភិបាលរាជធានីភ្នំពេញលេខ៨៣ ចុះថ្ងៃទី១៣-៥-១៩៩៨ បញ្ជាក់ថា អ្នកជំងឺឈ្មោះលឹម ហួង មានសភាពហើម និង មានការឈឺចាប់នៅតំបន់សន្ទាក់កដៃ ថតដោយកាំរស្មីអិច ក្បាលឆ្អឹង ការប៉ុទុស បែក និង បាត់បង់សមត្ថភាពពលកម្មចំនួន០២ខែ ។

-យល់ឃើញថា មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ភុំ កែវ ពីបទ បង្ករបួសស្នាមទៅលើជនរងគ្រោះឈ្មោះ លឹម ហួង បណ្តាលឱ្យមានរបួសស្នាមត្រង់កដៃប្រាកដមែន ដូចមានកោសល្យវិច័យ បញ្ជាក់ជាភស្តុតាងស្រាប់ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០៥"ខ" ចុះថ្ងៃទី១០-០២-២០០៤ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវ ទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី**

១-ទទួលបណ្តឹងសាទុក្ខលេខ២៤ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះ ភុំ កែវ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០៥"ខ" ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៥ ។